# បទសម្ភាសរបស់ យុយ ខួន

ក. អ្នកសម្ភាស ញ៉ែម សុកន្ធា ខ. យុយ ខួន

ក : អញ្ចឹងឥឡូវនាងខ្ញុំសូមខ្ចីការចាប់ផ្ដើមសម្ភាស អញ្ចឹងអ្នកមីងនាងខ្ញុំសូមអោយមីងជួយប្រាប់ឈ្មោះពេញមកនាងខ្ញុំម្ដងទៀតបានទេ?

ខ : ខ្ញុំឈ្មោះ យុយ ខួន ។

ក : ហើយអ្នកមីងមានឈ្មោះហៅក្រៅទេ?

ខ : អត់ មានឈ្មោះតែមួយ។

ក : អញ្ចឹងគេហៅតាមីងខួនៗអញ្ចឹងទៅ?
ហើយសម្រាប់អ្នកមីង តើថ្ងៃខែឆ្នាំកំណើតអ្នកមីងកើតថ្ងៃណាដែរ?

ខ : កើតឆ្នាំ១៩៧០។

ក : នៅថ្ងៃណាខែណាដែរមីង?

ខ : ថ្ងៃទី៧ខែ២។

ក : ចាស៎! ហើយទីកន្លែងកំណើតអ្នកមីងនៅណាវិញ?

ខ : នៅភូមិខាងលិចប្រាសាទ ស្រុកខាងលិចប្រាសាទ។

ក : ខេត្តណាដែរអ្នកមីង?

ខ : ស្រុកពាមរ ខេត្តព្រៃវែង។

ក : ចាស៎! ហើយសម្រាប់ដូចជាសព្វថ្ងៃហ្នឹងតើអ្នកមីងមានអាយុប៉ុន្មានដែរហើយ?

ខ : ខ្ញុំមានអាយុ អឺ...៤៧ហើយ។

ក : ចាស៎! ៤៧ហើយ អញ្ចឹងអ្នកមីងតើអ្នកមីងកើតឆ្នាំអីដែរ?

ខ : ខ្ញុំដូចជាអត់ចាំផង!

ក : ដូចជាជូត ឆ្លូវ ខាល ថោះ អីហ្នឹងណាតើមីងកើតសត្វមួយណាដែរ?

ខ : ស្វា

ក : អញ្ចឹងឆ្នាំវក?

ខ : ចាស៎ វក ។

ក : ចាស៎! អរកុណអ្នកមីងមែនទែនអ្នកមីង ហើយសម្រាប់បន្តទៀត តើអ្នកមីងមានបងប្អូនប្រុសស្រីប៉ុន្មាននាក់ដែរ?

ខ : ខ្ញុំមានបងប្អូនស្រីប្រាំមួយនាក់។

ក : ហើយស្រីម៉ានប្រុសម៉ាន?

ខ : ស្រីទាំងប្រាំមួយនាក់។

ក : អញ្ចឹងស្រីទាំងប្រាំមួយតែម្តង?

ខ : ចាស៎!

ក : ហើយអ្នកមីងជាកូនទីប៉ុន្មានដែរ?

ខ : ជាកូនទីប្រាំ។

ក : ហើយឥឡូវហ្នឹងតើបងប្អូនមីងនៅរស់ទាំងអស់គ្នាមែន ហើយរស់នៅណាដែរ?

ខ : ឥឡូវនៅបងប្អូនទាំងអស់ នៅបួននាក់។

ក : ហើយឥឡូវកាត់រស់នៅណាដែរ?

ខ : កាត់រស់នៅអីស្រុកមួយ នៅហ្នឹងបីនាក់ នៅភូមិស្វាយរលំ ភូមិលេខបួន ស្រុកស្អាង ខេត្តកណ្តាលម្នាក់។

ក : ចាស៎! អញ្ចឹងអ្នកមីងសព្វថ្ងៃអ្នកមីងរស់នៅជាមួយអ្នកណាគេដែរ?

ខ : ខ្ញុំរាល់ថ្ងៃរស់នៅជុំក្រុមគ្រួសារទាំងអស់គ្នា។

ក : ចាស៎! ហឺ... សម្រាប់ឪពុករបស់អ្នកមីងវិញតើកាត់មានឈ្មោះអីដែរ?

ខ : ឪពុកខ្ញុំកាត់ឈ្មោះ យុយ ហាក់ ។

ក : យុយ ហាក់ ចាស៎! ហើយអ្នកមីងដូចជាចាំបានថាតើកាត់កើតនៅទីណាទីអ្នកមីង?

ខ : កាត់កាលកាត់កើតនៅបឹងព្រះ។ អ៊ូ សុំទោសកាលកាត់កើតនៅដីថុយ។

ក : នៅណាវិញអ្នកមីង ដីថុយ?

ខ : អឺ... នៅជិតបាភ្នំនោះ ខេត្តព្រៃវែងដែរ។

ក : ខេត្តព្រៃវែងដែរ! ចាស៎ ហ៊ី...សម្រាប់កាត់អ្នកមីងមានចាំឆ្នាំកាត់កើតទេ?

ខ : អត់ចាំផងហ្នឹង!

ក : អត់ចាំទេ ហើយចុះឆ្នាំសត្វខ្មែរអញ្ចឹងណា?

ខ : អ៊ុ... អត់ចាំដែរ!

ក : អញ្ចឹងអត់ចាំដែរ អ៊ូ អញ្ចឹងដូចជាសម្រាប់ម្តាយរបស់អ្នកមីងវិញមានឈ្មោះអីដែរ?

ខ : ម្តាយខ្ញុំមានឈ្មោះ សុខ ព្រឹម ។

ក : សុខ ព្រឹម ចុះទីកន្លែងកំណើតវិញនៅណាដែរ?

ខ : នៅចាក់ខ្លាញ់ ។

ខ : នៅខេត្តព្រៃវែងដែរ ។

ក : ស្រុកអីគេវិញមីង ?

ខ : ស្រុកពាមរ ដូចក្នា។

ក : ចាស៎ ពាមរដូចក្នា ហើយអញ្ចឹងសម្រាប់អ្នកមីងមានចាំថ្ងៃខែឆ្នាំកំណើតយាយម្តាយអ្នកមីងអត់ ?

ខ : អត់ចាំដែរ។

ក : អូ អត់ចាំដែរ ចាស៎ ហើយចុះឆ្នាំខ្មែរកាត់វិញ ?

ខ : អត់ចាំដែរអត់ដែរបានសួរកាត់ផង។

ក : ចាស៎ អញ្ចឹងសម្រាប់ឪពុករបស់អ្នកមីងវិញតើកាត់បានស្លាប់ហើយមែនទេ ?

ខ : ចាស៎ ស្លាប់ហើយ។

ក : ចាស៎ អញ្ចឹងតើកាត់ស្លាប់នៅខែណាឆ្នាំណាដែរអ្នកមីង ?

ខ : នៅថ្ងៃទី៤ខែ៧ឆ្នាំ០០៤ ។

ក : អញ្ចឹងពេលដែរកាត់ស្លាប់តើកាត់អាយុម៉ានដែរមីង ?

ខ : អ៊ឹ... កាត់អាយុ៧៥។

ក : អញ្ចឹងពេលយើងដកអីទៅប្រហែលជាកាត់កើតនៅឆ្នាំណាដែរមីង ?

ខ : ១៩២០។

ក : ចាស៎ អញ្ចឹងហ្នឹងហើយយកដកទៅតាមហ្នឹង អញ្ចឹងសម្រាប់យាយវិញឥឡូវ កាត់មានអាយុម៉ានហើយយាយ ?

ខ : យាយ៨១។

ក : ចាស៎ អញ្ចឹងយាយ៨១ហើយ អញ្ចឹងកាត់កើតឆ្នាំណាដែរ ?

ខ : កាត់កើតឆ្នាំ១៩២៥៕

ក : និងហើយអញ្ចឹងសម្រាប់អ្នកមីងតើអ្នកមីងស្រលាញ់ឪពុកម្តាយមីងអត់ទេ ?

ខ : អឺ ខ្ញុំស្រលាញ់ឪពុកម្តាយខ្ញុំខ្លាំងណាស់៕

ក : អញ្ចឹងតើមីងមានការចង់ចាំអីដែរល្អៗអំពីឪពុកមីងអត់ ?

ខ : អ៊ឺ... បើនិយាយពីឪពុកខ្ញុំវិញគឺកាត់ជាមនុស្សស្លូតណាស់ អត់ចេះមាត់ចេះករ មិនដែរជេរកូនពាក្យថាម៉េង ហាងអីទេហើយក៏មិនដែរចេះវាយកូនសូម្បីមួយដៃ ជាតិនេះថ្វីត្បិតតែខ្ញុំកើតមកជាកូនអ្នកក្រពិតមែនប៉ុនតែខ្ញុំស្រលាញ់ឪពុកម្តាយខ្ញុំខ្លាំងណាស់ កាត់មានកុណមកលើខ្ញុំហើយកាត់ជាមនុស្សស្លូតមែនទែន។

ក : ចាស៎ ហើយចុះម្ដាយអ្នកមីងវិញ?

ខ : អ៊ឺ... បើម្ដាយខ្ញុំវិញកាត់ល្អ ប៉ុន្តែកាត់មាត់ឆេវឆាវបន្តិច តែមាត់ឆេវឆាវមិនដែរខ្វើអីមកលើកូនៗទេ ព្រោះឪពុកម្ដាយខ្ញុំមានការហត់នើយច្រើនដោយសារតែកាត់អត់មានកូនប្រុស៕

ក : ចាស៎! ហ្នឹងហើយ!

ខ : មានសុទ្ធតែកូនស្រីទាំងអស់ ៕

ក : ចាស៎ អញ្ចឹងសម្រាប់ជីដូនជីតារបស់មីងវិញអ្នកមីងចាំថាជីដូនជីតារបស់អ្នកមីងមានឈ្មោះថាអ្វីខ្លះ?

ខ : តាខ្ញុំឈ្មោះ តាយ៉ុយ តែមិនដឹងថាស្អីយុយទេភ្លេចបាត់ហើយ!

ក : ចុះយាយ?

ខ : ហើយយាយឈ្មោះយាយ ហេង។

ក : ចាស៎! អញ្ចឹងពួកកាត់ទាំងពីរនាក់ហ្នឹង តាយាយខាងណាដែរខាងម្ដាយរឺក៏ខាងឪពុក?

ខ : តាយាយខាងឪពុក។

ក : ចុះតាយាយខាងម្ដាយវិញ?

ខ : ខាងម្ដាយវិញ តាឈ្មោះតាសុខ យាយឈ្មោះយាយត្រាវ ។

ក : អញ្ចឹងអ្នកមីងដូចជាចាំថាពួកកាត់ឆ្នាំណាដែរ ហើយកើតថ្ងៃណាអត់?

ខ : ខ្ញុំកើតអត់ទាន់ទេ យាយខាងម្ដាយខ្ញុំកើតអត់ទាន់ទេ តែបើយាយតាខាងឪពុកកើតទាន់។

ក : ចាស៎ !អញ្ចឹងតើកាត់នៅស្រុកណាដែរ?

ខ : នៅចាក់ខ្លាញ់ ។

ក : នៅចាក់ខ្លាញ់ ស្រុកពាមរហ្នឹងដែរ។

ខ : ចាស៎!

ក : ហ្នឹងហើយ អញ្ចឹងមីងទាន់ដូចជាមានដឹងថាកាត់កើតឆ្នាំខ្មែរឆ្នាំអីកេអត់?

ខ: អត់ទាន់អត់ដឹងទេព្រោះកាត់មិនដែរបានប្រាប់ទេ។ អត់ទាន់ដឹងទេព្រោះកាត់មិនបានប្រាប់ តែដូចជាអ្នកមីងកើតទាន់លោកតាលោកយាយខាងឪពុកមីងខ្លះៗ។

ក : អញ្ចឹងតើអ្នកមីងបានដូចជាមានការចង់ចាំអ្វីខ្លះពីរ លោកតាលោកយាយរបស់អ្នកមីងនិងណា?

ខ : អ៊ឺ...បើលោកតាខ្ញុំកាត់កាលពេលខ្ញុំដឹងក្ដីកាត់បានបង្កើតមុខជំនួញ រកស៊ីមួយដូចដើរទិញពោតទិញសណ្ដែកអីហ្នឹង តែបើយាយខ្ញុំវិញបើតាមខ្ញុំដឹងគឺកាត់នៅតាផ្ទះទេ។

ក : ហើយកាត់មានដែលបាននាំអ្នកមីងទៅលេងណារឺមួយខ្ញើអីជាមួយអ្នកមីងទេ?

ខ : អឺ អត់ផង!

ក : អត់ទេ!គ្រាន់តែមកនិយាយលេងខម្មុតាៗទេ។

ខ : គ្រាន់តែមកលេងផ្ទះតាមខម្មុតាៗហ្នឹង
ព្រោះអ៊ឺ..ជីវភាពកាលហ្នឹងមានអ៊ឺ...នោះហើយកាលហ្នឹង មិនដឹងទៅលេងណាទេ
ដឹងតែពីរខ្វើស្រែចម្ការហ្នឹង។

ក : ចាស់! ហ្នឹងហើយ អញ្ចឹងមួយហ្នឹងសម្រាប់ប្រវត្តិរបស់អ្នកមីងអំពីសម្រាប់អំពីជីដូនជីតា
អញ្ចឹងណា អញ្ចឹងឥឡូវឈានចូលដល់ការសិក្សារបស់អ្នកមីងវិញអញ្ចឹងណា។
តើអ្នកមីងរៀនបានថ្នាក់ទីម៉ានដែរ?

ខ : ខ្ញុំរៀនបានថ្នាក់ទីបួន។

ក : នៅឆ្នាំណាអ្នកមីងរៀនហ្នឹង?

ខ : អ៊ឺ... ខ្ញុំឈប់រៀននៅឆ្នាំ៨២។

ក : ឆ្នាំ១៩៨២ អញ្ចឹងពេលនៅរៀនមីងរៀននៅសាលាណាដែរពេលហ្នឹងមីង?

ខ : រៀននៅសាលាប្រាសាទហ្នឹងតាម៉ង់។

ក : ចាស់! អញ្ចឹងអ្នកមីងកាលដែលអ្នកមីងនៅសិក្សាហ្នឹង អ្នកមីងដូចជាឆ្លាតចាប់ការសិក្សា
ហ្នឹងបានដែររឺទេ?

ខ : កាលខ្ញុំរៀនដូចជាអត់ឆ្លាតទេ ហើយម៉េចបានថាអត់ឆ្លាតព្រោះវាហាត់នឿយនិង
មិនសូវមានពេលរៀនសូត្រព្រោះបងប្អូនសុទ្ធតែស្រីចេញពីរៀនមកត្រូវទៅមើលកោ។

ក : ចាស់!

ខ : ចាស់ ហើយមកពីមើលកោអញ្ចឹងទៅ ជាន់ទឹករហាត់ទៅ កាលហ្នឹងមិនដែរដឹង
ស្រណុកម្តេចផងខ្ញុំ។

ក : ចាស់ សម្រាប់ក្តីស្រម៉ៃរបស់អ្នកមីងកាលពីក្មេងមីងខំឡើងចង់ខ្វើអីកេដែរ?

ខ : កាលពីក្មេងខ្ញុំចង់ខ្វើជាអ្នករៀនចេះដឹងម្នាក់ និងដើម្បីខ្វើជាគ្រូពេទ្យ។

ក : ចង់ខ្វើជាគ្រូពេទ្យ!

ខ : ហ្នឹងហើយស្រលាញ់ជាងគេគ្រូពេទ្យ ប៉ុន្តែវាមិនបានដូចបំណង។

ក : ចាស់ អត់អីទេអ្នកមីង! អញ្ចឹងតើអ្នកមីងមានខ្លាប់ខ្វើស្រែចម្ការអីទេ?

ខ : ខ្លាប់ខ្វើស្រែចម្ការពេលដែលខែទឹកឡើងអញ្ចឹងទៅកេរកមង ដាក់មងត្រី
មងពស់ទៅតាមតែដល់ពេលទឹកស្រកចាប់ផ្តើមស្ទូងស្រូវបណ្តោញទឹកហើយនិងដាំសណ្តែ
កដីនិងសណ្តែកបាយ
ដាំពោតខែដើមឆ្នាំដាំពោតខែទឹកឡើងរកត្រីខែទឹកស្រកដាំសណ្តែកដី។

ក : ចាស់! ការងារដាំដុះ ចាសអញ្ចឹងតើគ្រូសាររបស់អ្នកមីងមានអ្នកណាខ្វើការងារ

រកស៊ីអត់មីង?

ខ : បើតាមតែខ្ញុំខ្លាប់ដឹងក្រួសារខ្ញុំតាំងពីខ្ញុំនៅតូចរហូតមកដល់ក្រួសារខ្ញុំមិនដែលមានមុខ
ជំនួញអីផង ខ្វើតាស្រែចម្ការរហូតមក។

ក : ហើយមានខ្វើការអីខ្លះអត់ ការងាររាជការអីអត់?

ខ : អត់មានផង ។

ក : ចាស់ អញ្ចឹងសម្រាប់អ្នកមីងវិញកាលដែលសម័យអ្នកមីងនៅរៀន
តើមីងមានខ្លាប់បានរៀនភាសាអីទេកាលពេលពីជំនាន់មីងសិក្សាហ្នឹង?

ខ : អត់ផងរៀនតាខ្មែរសុទ្ធហ្នឹង ។

ក : អញ្ចឹងអ្នកមីងចេះអានចេះសរសេរទេ?

ខ : មកដល់ឥឡូវហ្នឹងចេះអានខ្លះចេះសរសេរខ្លះ?

ក : ចាស់ តែអាចមើលរួចអីហ្នឹងទាំងអស់?

ខ : ចាស់ អាចមើលរួច ។

ក : ចាស់ អញ្ចឹងល្អមែនទែនអ្នកមីងអាចអានអក្សរបានដូចជាចេះអញ្ចឹងទៅគេមិន
អាចបន្លំយើងបានអញ្ចឹងណា។ចាស់ អញ្ចឹងសម្រាប់អ្នកមីងវិញអ្នកមីងការនៅឆ្នាំណាដែរ?
ថ្ងៃណា?ខែណាដែរ?

ខ : ការអត់ចាំថ្ងៃ អត់ចាំខែអីទេចាំតែឆ្នាំហ្នឹង ឆ្នាំ៨៦។

ខ : ការរៀបការរបស់ខ្ញុំស្រលាញ់ចិត្តអែងអត់បានទេត្រូវតែតាមម៉ែតាមឪទាំងអស់។

ក : បើសិនជាមិនតាមម៉េចទៅមីង?

ខ : បើសិនជាមិនតាមកាត់ថាកូនមិនស្តាប់បង្គាប់ ហើយកាត់ថា “នំមិនដែលខ្ញុំជាងនៀល”
ក : ១៩៨៦ ចាស់! ហើយដូចជាការរៀបការរបស់អ្នកមីងម្តាយទុកឪពុកដាក់រឺក៏រៀបការ
ដោយស្រលាញ់ចិត្តអែង?

ទេតាម៉ែដាក់ទុកអោយនៅណាត្រូវតែទៅតាមហ្នឹងហើយប្តីរាល់ថ្ងៃជាប្តីដែរឪពុកម្តាយរៀបចាំ
អោយទេ។

ក : ហើយម្តេចដែរតើស្វាមីអ្នកមីងហ្នឹងតើកាត់មានអត្តចរិកម្តេចដែរ?

ខ : កាត់មានអត្តចរិកស្លូតបូតកាត់មិនចេះអក្សរទេហើយមិនសូវចេះមាត់ទេស្លូតដឹង
តែពីខ្វើការដឹងតែពីខ្វើដឹងតែពីរក។

ក : អញ្ចឹងកាលពីពេលមីងការហ្នឹងហើយខាងស្រីហ្នឹងមានទារបណ្តាការអីខ្លះពីខាងប្រុសទេ?

ខ : ខាងស្រីអត់ទារបណ្តាការពីខាងប្រុសទេសុំតែមួយរួចខ្លួនកាត់យកខ្ញុំហ្នឹងទៅអោយ
ខាងប្រុសការព្រោះកាត់ថាកាត់ទើបតែការកូនស្រីហើយច្រើនណាស់ការមួយឆ្នាំពីរមិនបាន
ទេ ដល់ហើយខាងប្រុសគេបង្ខំអញ្ចឹងទៅកាត់ថាបើស្រលាញ់ហើយទ្រាំចាំមិនបានយក
ទៅណានៅផ្ទះខ្លួនអែងទៅហើយកែយកទៅការអោយមែន។

ក : ដល់ខាងណោះគេលែងចាំហើយហ្នឹងអញ្ចឹងខាងប្រុសបង្ខំអោយការតាម៉ង់ កំប្លែងណាស់មីង!តែជាជីវិតរបស់មីងផ្ទាល់។
អញ្ចឹងសម្រាប់មីងជីវិតរបស់អ្នកមីងកាលពីអតីតកាលនិងពេលបច្ចុប្បន្ន តើមានលក្ខណ:ខុសគ្នាម៉េចខ្លះដែរ?

ខ : ខ្ញុំនិយាយពីដឹងក្តីមកមិនដែលថាស្គាល់ពាក្យស្រណុកម្តេចទេដឹងតែពីការ ឈឺចាប់ដឹងតែពីរការសោកពីព្រោះកាលនៅពីក្មេងនៅតែជាមួយម្តាយក៏ហត់នឿយ និងការរកចរិកាជួយម្តាយកាត់ក្រហើយបងប្អូនស្ទូតែស្រីដល់ពេលមករៀនក៏មិនបានជ្រៅជ្រះ ហើយដល់ពេលមកមានប្តីហត់នឿយទាំងការរកចំណូលហត់នឿយទាំងការស្វះស្វែងរកស្អី ទាំងអស់ដូចជាបន្ទុកនៅលើទាំងអស់អញ្ចឹង។

ក : ចាស៎ អាហ្នឹងបើវាពិបាកអញ្ចឹងហើយ អញ្ចឹងជីវិតរបស់អ្នកមីងបែបហ្នឹងហើយចុះអញ្ចឹង ខ្ញុំសូមឈានចូលដល់ចំណុច តើអ្នកមីងចូលចិត្តពិសាម្ហូបអីកេដែរ?

ខ : ខ្ញុំកិតទៅអត់រើសផង។

ក : តែអីកេដែរឆ្ងាញ់ជាងគេបំផុតសម្រាប់មីងណា?

ខ : ឆ្ងាញ់ជាកេបំផុតសម្រាប់ខ្ញុំកឺឆាក្រៀង ហ្នឹងបានខ្ញុំចូលចិត្តតែឆាហ្នឹងណា!

ក : អញ្ចឹងបានជាខ្ញុំឃើញមីងឆាអាហ្នឹងទៀតហើយមកពីមីងចូលចិត្តអញ្ចឹង។
ចាស៎ ហ្នឹងហើយអញ្ចឹងអ្នកមីងចេះខ្ទឹម្ហូបទាំងអស់ហ្នឹងតើមែនទេ?

ខ: ចាស៎!

ក : ចាស៎ អញ្ចឹងតើអ្នកមីងរៀនខ្ទឹម្ហូបទាំងអស់ហ្នឹងតាមណាកេដែរ?

ខ : ខ្ញុំរៀនខ្ទឹម្ហូបតាមបងៗស្រីខ្ញុំមក។

ក : អញ្ចឹងអ្នកមីងអាចបង្ហាញខ្លះៗអំពីរបៀបម្ហូបដែរអ្នកមីងចូលចិត្តឆាក្តៅហ្នឹង កេខ្ទឹរបៀបម្តេច?

ខ : ឆាក្តៅហ្នឹងដំបូងឡើងបើយើងឆាក្តៅឆ្អឹងជំនីជ្រូកកឺយើងត្រូវកាប់ឆ្អឹងហ្នឹងជាកង់ៗសិន ទៅហើយយើងបុកក្រៀងទាំងអស់ហើយស៊ព្វក្រប់ទៅយើងដាក់ឆ្នាំងខ្លាញ់បន្ទាប់មកដាក់ ខ្ទឹមលីងហើយដាក់ក្រៀងលីងហើយយើងដាក់ក្រៀងក្រៅ ហើយចាំយើងចាក់សាច់ចូលអោយ វាស្ងួតទឹកទៅ។

ក : ហើយមានដាក់បន្លែអីទេខ្លះទៀតទេមីង?

ខ : បើបន្លែចិត្តខ្ញុំចំនង់ចំណូលចិត្តមានតែសណ្តែកកួរហ្នឹងហើយ។

ក : ចាស៎ ឆ្ងាញ់តាម៉ង់មីងណោះ ខ្ញុំក្រាន់តែលឺឃ្លានណាស់មីង!អញ្ចឹងតើពេលទំនេរ តើអ្នកមីងចូលចិត្តខ្ទឹអ្វើដែរ?

ខ: ក្រៅពីខ្ទឹការ ខ្ញុំចូលចិត្តនិងតែងតែមានសៀវភៅដូចជាព្រះកម្ពីរខ្ញុំតែងតែយកមក មើលយ៉ាងហោចណាស់ក៏បានមួយសន្លឹកទៅពីរសន្លឹងដែរ ហើយខ្ញុំចូលចិត្តរៀបចំផ្ទះ ចូលចិត្តមើលក្នុងផ្ទះខ្ញុំហ្នឹងតើខ្ញុំគួររៀបរបៀបម្តេច?ក្នុងនៅតែក្នុងផ្ទះហ្នឹងដូចកេថាមនុស្ស ស្រីវិលចង្រ្កានមិនជុំទេ។

ក : អញ្ចឹងមីងតើពេលដែរមីងមានពេលទំនេរជាមួយក្រួសារកន្លែងណាដែរមីងចូលចិត្ត ទៅកំសាន្តជាងគេ?

ខ : និយាយរួមខ្ញុំមិនដែលចេះដើរកំសាន្តអីផងក្រុមគ្រួសារខ្ញុំចាប់តាំងពីបានក្នាមកមិន
ដែលបានទៅកំសាន្តនៅណាទេ។

ក : អុំញ! មិចអញ្ជឹងមីង?

ខ : ពីព្រោះអត់មានថវិកាដើរលេងទេហើយណាមួយគ្រួសារខ្ញុំកាត់មិនចេះដើរលេងទេ។

ក : ចាស់ ហើយអញ្ចឹងអ្នកមីងតើអ្នកមីងចេះច្រៀងទេអ្នកមីង?

ខ : អត់ទេ!

ក : ហើយអញ្ជឹងចូលចិត្តស្តាប់បទចម្រៀងអត់?

ខ : ចាស់ចូលចិត្ត។

ក : អញ្ជឹងបទហ្នឹងមានលក្ខណ:បែបណាដែរមីង?

ខ : បទហ្នឹងមានលក្ខណះបែបកម្សត់ៗ។

ក : បទកម្សត់ៗហ្នឹងហើយអញ្ចឹងតើបទហ្នឹងពីណាគេអ្នកច្រៀងដែរបទដែលអ្នក
មីងចូលចិត្តហ្នឹង?ហើយចូលចិត្តតារាចម្រៀងណាជាងគេដែរ?

ខ : បើតារាចម្រៀងសម័យឥឡូវនហ្នឹងដូចជាអត់ចូលចិត្តទេ ។

ក : អញ្ជឹងចូលចិត្តអ្នកណាជាងគេបទសម័យមុនអញ្ជឹង?

ខ : តារាចម្រៀងសម័យមុនចូលចិត្តដូចជាប៉ែន រ៉ន និងស៊ិន ស៊ីសាមុត។

ក : អុំ ល្បីម៉ង់កាត់ពីរនាក់ ចាស់! អញ្ជឹងបងប្អូនអ្នកមីងមានអ្នកណាចេះច្រៀង
ពីណាចេះប្រើប្រាស់ឧបករណ៍ភ្លេងខ្លះអី ?

ខ : អត់ទាំងអស់

ក : ហុឺ... ដូចជាអ្នកមីងកើតមុនសម័យប៉ុលពតមែនអត់អ្នកមីង?

ខ : ចាស់!

ក : ចាស់ អញ្ចឹងអ្នកមីងអាចប្រាប់ខ្ញុំបានបន្តិចថាព្រឹត្តិការណ៍ក្នុងជីវិតមីងអ្នកមីងបានជួបនឹង
អីគេខ្លះ?ហើយអ្នកមីងបានទៅរស់នៅក្នុងខេត្តណាដែរកាលសម័យប៉ុលពតនោះ?

ខ : នៅស្រុកដដែល។

ក : នៅ.....?

ខ : នៅពាមរហ្នឹងដដែលនិងភូមិខាងលិចប្រាសាទ ឃុំខាងលិចប្រាសាទ ស្រុកពាមរ ខេត្តព្រៃវែង
ហើយកាលជំនាន់ប៉ុលពតនិយាយទៅវាមិនបានរៀនសូត្រអីទេទៅរៀនចូលទៅដល់ក្នុងសាលា
អញ្ចឹងទៅគ្រូបង្រៀនអង្គុយនៅលើជុំថ្មបង្រៀនមួយម៉ាត់ពីរម៉ាត់អញ្ចឹងទៅស្រះ អ ស្រះ អា
អញ្ចឹងប្រើអោយទៅបេះត្រកួនហើយរែសាយនាំគ្នាទៅបេះត្រកួនមួយបាច់ពីរបាច់អញ្ជឹងទៅ
ទៅដេញចាប ហើយកាលជំនាន់ហ្នឹងវេទនាណាស់ដែរគ្មានបានរៀនសូត្រ។

ក : អញ្ចឹងដូចជាការជំនាន់ហ្នឹងតើការហូបចុករបស់មីងមិចដែរ?

ខ : ការហូបចុកជំនាន់ហ្នឹងមានដល់ថ្នាក់អត់បាយអត់អង្ករដាំបងប្អូនខ្ញុំដែលខំៗហ្នឹងនាំគ្នាទៅដកមើមឈូកហើយជូនកាលយកក្រប់វាមកលាយបាយញ៉ាំជូនកាលបានពោតក្រហមបុកលាយបាយវេទនាណាស់។

ក : ហើយអញ្ចឹងដូចជាបងប្អូនរបស់អ្នកមីងទាំងអស់ហ្នឹងនៅក្នុងជំនាន់ប៉ុលពតហ្នឹងទាំងអស់គ្នាហ្នឹងកាត់បានរួចជីវិតរឺក៏កាត់មានជួបបញ្ហាអីដែរ?

ខ : កាត់និយាយរួមបងប្អូនខ្ញុំកាត់ចូលបានចូលយុទ្ធនារីខ្លះនៅកុមារខ្លះហើយប្អូនស្រីខ្ញុំនិងខ្ញុំហ្នឹងមិនទាន់បានចូលយុទ្ធនារីអីទេប៉ុន្តែកេប្រើជូនកាលសែងដីសែងអីអញ្ចឹងទៅ។

ក : ចាស៎!

ខ : ពិបាកណាស់ខុសពីឥឡូវហ្នឹងឆ្ងាយណាស់។

ក : ចុះមីងខ្ញុំបានលឺថាកាលសម័យនោះកេសម្លាប់មនុស្សសាហាវៗណាស់មែនទេមីង? តើមីងមានបានខ្លាប់ឃើញរឿងមួយហ្នឹងទេ?

ខ : ខ្ញុំមិនដែលខ្លាប់ឃើញកេសម្លាប់ផ្ទាល់ភ្នែកទេប៉ុន្តែ លឺតែកេថាៗសម្លាប់មនុស្សអាការនឹងខាងត្នោតហើយយកខាងត្នោតនឹងខ្វើដូចជារណារ ហើយនិងវាយហ្នឹងត្បូងចបហើយទម្លាក់ទៅក្នុងអណ្តូង។

ក : មីងនិយាយអញ្ចឹងខ្ញុំព្រឺសម្បុរ!

ខ : ហើយនៅស្រុកម្តាយខ្ញុំហ្នឹងកេមានឈ្មោះមួយកុកទួលស្លែង។

ក : ចាស៎ កន្លែងកេសម្លាប់មនុស្សនោះ!

ខ : ចាស៎! ឥឡូវមានតែឈ្មោះទេ!

ក : អញ្ចឹងសម្រាប់ជីវិតរបស់មីងតើពេលវេលាដែលមីងពិបាកជាងកេបំផុតនៅក្នុងជីវិតតើពេលណាដែរ?

ខ : ជាពេលវេលាបែកជំនាន់ស្អីទេខ្ញុំដូចជាមិនសូវចាំទេកេហៅជំនាន់ស្អីទេ!

ក : ជំនាន់លន់ នល់មែន?

ខ : មែនទេមិនមែនជំនាន់លន់ នល់ទេ ស្អីទេខ្ញុំភ្លេចត្រង់និងហើយរត់ចោរស្រុករត់ចោលផ្ទះរត់ចោលសម្បែង។

ក : ហើយចឹបានរត់មីង? ហេតុអី?

ខ : កាលហ្នឹងកេវាយ ក្នាផ្លោងក្រាប់បែកនោះ!

ក : អូ៎ អញ្ចឹងមានតែជំនាន់ លន់ នល់ហ្នឹងហើយអញ្ចឹង។

ខ : ហ្នឹងហើយសម័យហ្នឹង ហើយអញ្ចឹងហ្នឹងហើយរត់ទៅឪពុកខ្ញុំហ្នឹងកាត់ទូលហើយបងៗស្រីខ្ញុំហ្នឹងកាត់រែកឪពុកខ្ញុំចេះតែរត់ទៅៗហើយយប់ត្រង់ណាដេកត្រង់ហ្នឹងរស់ដោយវេទនាណាស់ទម្រាំបានប៉ុណ្ណឹងនោះមកដល់សព្វថ្ងៃ។

ក : ហ្នឹងហើយគ្រាន់តែបិទភ្នែកហើយដេកស្រម៉ៃក៏វេទនាដែរមែនទេមីងណោះ?

ខ : ហ្នឹងហើយវេទនាណាស់។

ក : ចាស់! កិតទៅរបបពិបាកៗណាស់សង្គ្រាម ហើយអញ្ចឹងសម្រាប់បងប្អូនសាច់ញាតិ អីហ្នឹងឪពុកម្ដាយមីងមានបានរួចផុតពីរបបហ្នឹងអត់?

ខ : កាត់បានរួចផុតអស់ហើយ។

ក : អញ្ចឹងតើមីងមានបងប្អូនជីដូនមួយរឺក៏សាច់ញាតិអីអត់ដែរបានស្លាប់កាលជំនាន់ហ្នឹងអត់?

ខ : មានដូចជាមីងបង្កើតខាងម្ដាយ ពូខាងម្ដាយ មីងខាងម្ដាយ។

ក : អញ្ចឹងកាត់ស្លាប់ច្រើនដែរ!

ខ : ចាស់! ស្លាប់ច្រើនណាស់និយាយទៅបើតាមខ្ញុំដឹងច្រើនជាងគេខាងម្ដាយ បីទៅបួននាក់ ក្រោយពេលជម្លៀសហើយដាក់កាណូតទៅវាយចោលតាម៉ង។

ក : ចាស់!ហើយចុះអ្នកមីងមានអារម្មណ៍យ៉ាងម៉េចដែរនៅពេលជំនាន់មួយហ្នឹងណា?

ខ : បើកិតពីជំនាន់មួយហ្នឹងមានអារម្មណ៍ថាឈឺចាប់ណាស់ ហើយក៏មានអារម្មណ៍ថា នឹកឃើញជំនាន់ហ្នឹងហើយដូចបើជាមានជំនាន់ហ្នឹងទៀតនឹកអានិតកូនៗនិងក្មេងៗសម័យ ឥឡូវណាស់បន់អោយវាជៀសសង្គ្រាមទៅព្រោះកាលសម័យនោះវេទនាណាស់កិតៗទៅ គេហៅប្រជុំម្ដងៗគេប្រើ ហើយការក៏វេទនាកេចាប់ដាក់ៗព្រោះបងស្រីខ្ញុំខ្លាប់មានការជំនាន់ ប៉ុលពតហ្នឹងមួយដែរមិនដែរស្គាល់គ្នាហើយក៏មិនដែលស្រលាញ់គ្នាដែរចាប់ផ្ទុំតាម៉ង់។

ក : ហ្នឹងហើយ ចុះបន្ទាប់ពីបែករបបប៉ុលពតហ្នឹងមករួចផុតជំនាន់ ហ្នឹងមកមានអារម្មណ៍ម៉េចដែរ?

ខ : មានអារម្មណ៍សប្បាយព្រោះយើងបានរួចផុតពីរការវេទនាការស្រែកឃ្លានទាំងប៉ុន្មាន ដែរយើងខ្លាប់ជួបពីរមុនមកដូចថាមានការសប្បាយចិត្តដូចថាយើងរស់ឡើងវិញអញ្ចឹង។

ក : ហ្នឹងហើយដូចមួយៗតែងនិយាយថាដូចរស់ឡើងវិញអញ្ចឹង!អញ្ចឹងបន្ទាប់ពីបែក ពីសម័យនោះមកតើអ្នកមីងបានប្រកបរបរចិញ្ចឹមជីវិតដោយអ្វីដែរ?

ខ : ដូចជាខ្ញុំនិយាយមិញហ្នឹងអញ្ចឹងខ្ញីស្រែចម្ការរហូតទាល់តែមានគ្រួសារម៉ែឪរៀបចំ អោយអញ្ចឹងទៅរស់នៅជាមួយគ្រួសារអញ្ចឹងទៅ។

ក : អញ្ចឹងសម្រាប់ជីវិតរបស់មីងចង់ចាំបំផុតអីគេដែរ? តើពេលណាដែលមីងចង់ចាំមិនអាច បំភ្លេចបាន?

ខ : ការចង់ចាំមិនអាចបំភ្លេចបានពេលដែលកើតមកជំនាន់ លន់ នល់មើលទៅដូចជា វេទនាណាស់តែដល់ពេលរួចផុតពីរជំនាន់ហ្នឹងទៅដូចជាបានរស់សារថ្មីអញ្ចឹងជំនាន់ ហ្នឹងវេទនាជាងគេអត់អីហូបទៅយប់គ្រង់ណាទម្រាំតែបានបាយហូបយប់ផងងងឹតផង។

ក : ចាស់! ចុះសម្រាប់សម័យ លន់ នល់ ហ្នឹងសម័យប៉ុលពតជីវិតអ្នកមីងដូចតែគ្នារឺក៏ម៉េចដែរ?

ខ : ដូចតែគ្នាហ្នឹងវេទនាពិបាកជួបហូបបបរហូបមិនដែលឆ្អែតទេថ្ងៃណាក៏ម្ហូរត្រកួនៗដែរ។

ក : នៅពេលហ្នឹងតើសម្បូរម្ហូបអត់រឺក៏ពួកវាមិនអោយហូបយើងហូបតាម៉ង់?

ខ : គិតទៅម្ហូបបើឆ្ងាញ់គេយកទៅអោយតែពួកប្រខានសហាករស្មើកេទេកិតទៅពួកប្រជាជនខម្មើតាមិនដែលបានទាំងឃើញសាច់ផងថ្ងៃណាក៏ម្នូរត្រកួនដែរ។

ក : អញ្ចឹងសម្រាប់អ្នកមីងបានរៀបការរួចហើយអញ្ចឹងកាលពីការហើយតើអ្នកមីងមានកូនប៉ុន្មាននាក់ដែរ?

ខ : ខ្ញុំមានកូនដែរ បានកើតមកឃើញព្រះអាទិត្យដែរ កើតចេញពីផ្ទៃខ្ញុំផ្ទាល់ហ្នឹងមានចំនួនបួននាក់។

ក : ហើយកាត់មានឈ្មោះអីខ្លះដែរអ្នកមីងអាចជួយរៀបរាប់ឈ្មោះពេញប្រាប់ខ្ញុំផងបានទេមីង?

ខ : កូនទីមួយឈ្មោះ ជុំ សុជាតិ កូនទីពីរឈ្មោះ ជុំ សុខី កូនហ្នឹងកើតបានតែបីថ្ងៃទេ ទីបីឈ្មោះ ជុំ សុផាន់ណា ហើយកូនទីបួនឈ្មោះ ជុំ សីហា។

ក : អញ្ចឹងកូនទីពីរហ្នឹងកាត់កើតបានតែបីថ្ងៃកាត់ស្លាប់?

ខ : ចាស៎!

ក : អញ្ចឹងអ្នកមីងមានកូនចិញ្ចឹមអីអត់?

ខ : មានកូនខមិមួយស្គាល់ក្នាបានរយៈពីរឆ្នាំដែរឥឡូវកាត់ទៅស្រុកកេបាត់ហើយទើបតែទៅថ្មីៗដែរហ្នឹង។

ក : ចាស៎! ហើយកាត់ឈ្មោះអីកេដែរមីង?

ខ : កាត់ឈ្មោះ អ៊ី...ឈ្មោះកេវែងណាស់ខ្ញុំពិបាកហៅណាស់?

ក : អត់ចាំឈ្មោះ?ដូចជាឈ្មោះអ្នកមីងចាំតាមួយម៉ាត់ៗអីណា?

ខ : ឈ្មោះសីហាដូចកូនខ្ញុំដែរ។

ក : ហើយចុះស្វាមីអ្នកមីងឈ្មោះអីកេដែរ?

ខ : ឈ្មោះ សំ ជុំ ។

ក : ហ៊ឺ...ឥឡូវហ្នឹងអ្នកមីងដូចជារបៀបដែលមីងចិញ្ចឹមបីបាច់ថែរក្សាកូនហ្នឹងចិញ្ចឹមកូនយ៉ាងម៉េចដែរដើម្បីអោយដើរតាមកន្លងខមិ?

ខ : ចាស៎! ខ្ញុំឥឡូវនៅតែកូនពីរនាក់ទេ នៅកូនស្រីមួយកូនប្រុសមួយ ប៉ុន្តែខ្ញុំស្រលាញ់កូនហ្នឹងខ្លាំងណាស់និងប្រដែលប្រដៅកូនខ្ញុំទាំងពីរអោយដើរតាមកន្លងខមិថ្វីត្បិតតែយើងក្រ ហើយកូនខ្ញុំចេះស្តាប់បង្គាប់បានល្អអត់ចេះដើរលេង តាមតែចិត្តតាមកន្លងខមិដូចដែរអ្វីដែរយើងកិតណាស់។

ក : អញ្ចឹងល្អមែនទែនអ្នកមីង អញ្ចឹងអ្នកមីងមានអោយពួកកាត់ទៅរៀនបានទាំងអស់ក្នាអត់?

ខ : អោយទៅរៀនកូនស្រីហ្នឹង អោយទៅរៀនពីថ្នាក់ទីមួយរហូតដល់ថ្នាក់ទីប្រាំពីរហើយ វាឃំថាវារៀនអត់កើតទេវារៀនមិនចូលទេដូចជាវាខ្វះប្រាជ្ញា ហើយកូនស្រីហ្នឹងវារៀនមិនកើតមែន ហើយរាល់ថ្ងៃហ្នឹងនៅតែកូនប្រុសពៅមួយទេទោះបីក្រទោះបីអត់ម៉េចក៏ខំប្រឹងអោយកូនរៀនដែរ

ទាំងភាសាខ្មែរនិងភាសាអង់គ្លេស។

ក : ល្អមែនទែនអ្នកមីង! អញ្ចឹងអ្នកកោលបំណងអ្នកមីងកាលពីក្មេងអ្នកមីងចង់ក្លាយទៅជាពេទ្យអញ្ចឹងអ្នកមីងមានកិតចង់ផ្គត់ផ្គង់អោយកូនអ្នកមីងបានខ្ញើជាពេទ្យដើម្បីសម្រេចក្ដីស្រម៉ៃរបស់អ្នកមីងទេមីង?

ខ : ចង់!

ក : ចង់អោយកាត់ខ្ញើជាពេទ្យ។ អញ្ចឹងមូលហេតុអីដែរអ្នកមីងកិតថាការសិក្សាហ្នឹងវាល្អសម្រាប់កាត់ តើការសិក្សាតាមកំនិតរបស់កាត់មានតម្លៃយ៉ាងណាដែរ?

ខ : ការសិក្សាវាមានតម្លៃណាស់សម្រាប់មនុស្សគ្រប់រូបនោះ ព្រោះបើរៀនបានខ្ពង់ខ្ពស់ចេះច្រើនភាសាច្រើនអញ្ចឹងមនុស្សហ្នឹងមានភាពថ្លៃថ្នូរម្នាក់នៅក្នុងសង្គម ខ្ញើអ្វីមួយដូចជាអ្នកចេះដឹងទៅណាអ៊ុ...ដូចថា.....!ប៉ុន្តែដោយមនុស្សទើអ្នកខ្លះរៀនបានខ្ញើការប្រាក់ខែច្រើនតែប៉ុន្តែនៅតែផ្លាត់ស្មៀតទៅជាមនុស្សខូចទៅវិញតែមួយពព្រិចភ្នែកដូចជាមនុស្សដែលដើរខុសតែមួយភ្លែតអញ្ចឹងល្អយូរហើយតែមកអាក្រក់តែមួយពព្រិចភ្នែក។

ក : អញ្ចឹងសម្រាប់អ្នកមីង តើមីងមានវិខានការអ្វីទេដើម្បីខ្ញើការទប់ស្កាត់កុំអោយកូនចៅមីងដើរនៅលើផ្លូវមួយហ្នឹង?

ខ : ខ្ញុំតែងតែនិយាយថាកូនអើយកូនខំរៀនទៅ ម្ដាយគ្មានទ្រព្យសម្បត្តិអីចែកអោយទេមានតែលុយដែរម៉ែបង់ថ្លៃសាលាអោយកូនមួយខែៗដែរម៉ែប្រឹងរកអោយកូនរៀនសុំតែម្យ៉ាងកត់សុំអោយកូនរៀនហើយកូនដើរក្នុងផ្លូវល្អហើយរស់នៅក្នុងសង្គមអោយមានតម្លៃ។

ក : ចាស៎! ល្អមែនទែនអញ្ចឹងសម្រាប់អ្នកមីង តើអ្នកមីងខ្ញើយ៉ាងណាដើម្បីអោយគ្រួសាររបស់មីងមានសុភមង្គល?

ខ : ខ្ញុំរាល់ថ្ងៃចង់អោយគ្រួសារខ្ញុំមានសុភមង្គលណាស់ មិនថាខ្ញុំប្រឹងប្ដីខ្ញុំប្រឹងកូនខ្ញុំប្រឹង ខ្ញុំខំខ្ញើការអោយមានផ្ទះនៅអោយបានហូបគ្រប់គ្រាន់ស្លៀកពាក់គ្រប់គ្រាន់ដើម្បីអោយអ្នកភូមិដឹងថាគ្រួសារយើងជាមនុស្សសុចរិតគ្រួសារយើងជាមនុស្សល្អហើយយើងក៏មានការសប្បាយចិត្តពេលដែលអ្នកផ្សេងមើលមកគ្រួសារយើងហើយពួកខ្ញុំគ្មានកំនិតថាខ្ញើអ្វីមួយអោយខុសនឹងសង្គមទេ។

ក : អញ្ចឹងល្អមែនទែនអ្នកមីង! ចាស៎ សម្រាប់ក្រុមគ្រួសារ តើមានអត្ថន័យយ៉ាងណាសម្រាប់ជីវិតរបស់អ្នកមីងដែរ?ហើយអ្នកមីងចង់រស់នៅជាមួយកាត់ជារៀងរហូតអត់?

ខ : ខ្ញុំមិនដែរចង់បែកពីកាត់ទេ ថ្វីត្បិតតែកាត់ជាមនុស្សល្ងង់ពិតមែនប៉ុន្តែកាត់ជាមនុស្សស្លូតអ្នកខ្លះគេថាមនុស្សល្ងង់ពិបាករស់នៅជាមួយណាស់ ពិតមែនតែពេលណាដែលកាត់មានបញ្ហាក៏ហឹងកាត់ឆេវឆាវណាស់ខ្ញុំតែងតែអត់យើងអញ្ចឹងបានគ្រួសារយើងសុខសាន្តមកទល់ពេលហ្នឹងណាហើយឈ្លោះគ្នាកុំអោយអ្នកជិតខាងគេថាយើងខាំឈ្លោះប្រកែកគ្នាដូចឆ្កែហើយបើមកយកគ្នាជា
គ្រួសារវិញខ្ញុំខ្ញើមិនបានទេអញ្ចឹងយើងកុំខ្ញើអោយមានបញ្ហាអីទេ។

ក : ចាស៎ អញ្ចឹងអ្នកមីងមានវិខីសាស្រ្តអីដើម្បីខ្ញើអោយគ្រួសារមីងមានសុភមង្គល?

ខ : ខ្ញុំមានវិខីសាស្ត្រខំប្រឹងរកលុយ ថ្វីត្បិតតែស្វាមីខ្ញុំកាត់ចូលចិត្តហូបស្រាកាត់ជេរក៏ដោយក៏ខ្ញុំតែងតែអត់តែងតែមនតបមិនតពេលខ្លះពិបាកពេកតែងតែដេកលួចយំតែឯងមិនអោយកូនដឹងទេកុំអោយគេបារម្ភពីយើងហើយតែងតែអត់ខ្មត់។

ក : អញ្ចឹងតែងតែអត់ខ្មត់ណោះអ្នកមីង?
អញ្ចឹងសម្រាប់សំនួរមួយទៀតជាសំនួរចុងក្រោយហើយអ្នកមីងដូចជាសម្ភាសន៍ហ្នឹងដើម្បីទុកប្រវ

ត្តិមួយសម្រាប់អោយកូនចៅអ្នកមីងជំនាន់ក្រោយកាត់បានដឹង តើអ្នកមីងចង់ចែកចាយបទ
ពិសោខល្អក្នុងជីវិត និងទុកសម្រាប់ស្តាប់នូវការទូន្មាន សម្រាប់ពួកកាត់អញ្ចឹងណា?

ខ : ជាចុងក្រោយខ្ញុំសូមផ្តាំទៅកូនស្រីកូនប្រុសខ្ញុំថាបើសិនជាកូនមានគ្រួសារ
ការរស់នៅជាមួយគ្នាបើមានមួយខុសមួយទៀតក្លូវតែអត់អោនអោយគ្នាកុំឆាំងទៅឆាំមកកុំខ្ញើ
អោយគ្រួសារយើងល្អក់កករអីហើយនាំតែប្រេះឆាគ្នាទេហើយត្រូវតែយកម៉ែកំរូព្រោះម៉ែតែងតែខ្ញើ
អញ្ចឹងចឹងហើយកូនកុំឆ្មើងឆ្មៃជាមួយបងប្អូនអ្នកស្រុកអ្នកភូមិអីហើយកូនកុំដើរផ្លូវអាក្រក់សាច់ញ្ញា
ត្តិរីបងប្អូនណានាំកូនទៅផ្លូវអាក្រក់កូនត្រូវណែនាំទៅកែបើកូនដើរតាមកន្លងខមិជាផ្លូវហើយនាំកែ
អោយស្អុដូចកូនដូចជាខ្ញុំរស់នៅរាល់ថ្ងៃខ្ញុំតាំងចិត្តថាខ្ញុំនឹងខ្ញើអោយល្អសម្រាប់កូនខ្ញុំ។

ក : ចាស៎ អញ្ចឹងអរកុណមែនទែនអ្នកមីងសម្រាប់ការសម្ភាភាសថ្ងៃហ្នឹង ខ្ញុំដឹងថានឹងបានលឺដល់
កូនចៅអ្នកមីងជំនាន់ក្រោយនឹងបានលឺពីសម្លៀងអ្នកមីងផ្ទាល់តែម្តងអរកុណអ្នកមីងសម្រាប់ថ្ងៃ
ហ្នឹងហើយខ្ញុំមានតែប៉ុណ្ណឹងទេថ្ងៃនេះ អរកុណាច្រើនអ្នកមីង។

ខ : ចាស៎! អរកុណច្រើនដូចគ្នាអូនសូមអោយមានសំណាងល្អ!

ក : ចាស៎មីង អរកុណ!